## ២-សេចក្តីសំរេច

រាជធានីភ្នំពេញថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០០

### សេចក្តីសំរេចលេខ ១៨ សសរ

### ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង បង្រ្កាបការធ្វើ អាជីវកម្មបញ្ចាំង និង លក់កាសែ្សតវីដេអូអាសអាភាស ក្នុងព្រះរាជាណាចក្រកម្ពុជា

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

### សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីត្រួតពិនិត្យ និងចាត់វិធានការបង្រ្កាបរោងបញ្ចាំងវីដេអូអាសអាភាស និង ការលក់កាសែ្សតអាសអាភាសទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

១-លោក ឃឹម សារិទ្ធ អគ្គនាយករងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាប្រធាន

២-លោក សៅ ម៉ិនធឿន អនុប្រធាននាយកដ្ឋានពត៌មានទូទៅក្រសួងមហាផ្ទៃ ជាអនុប្រធាន

៣-លោក គង់ កន្លារ៉ា អនុប្រធាននាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ ជាសមាជិកអចិន្ត្រៃយ៍

៤-លោក ឃង់ ជូនណារិទ្ធ អនុប្រធានការិយាល័យនៃនាយកដ្ឋានពត៌មានទូទៅក្រសួងមហាផ្ទៃ ជាសមាជិក

៥-លោក វរសេនីយ៍ត្រី សារិទ្ធ ឈុន នាយកដ្ឋានឃោសនាសាធារណៈក្រសួងការពារជាតិ ជាសមាជិក

៦-លោក វរសេនីយ៍ត្រី រាជ សុខឃាង នាយកដ្ឋានអធិការកិច្ចទូទៅ ក្រសួងការពារជាតិ ជាសមាជិក

៧-លោក គឹម សារិន មន្ត្រីនាយកដ្ឋានសោតទស្សន៍ ក្រសួងពត៌មាន ជាសមាជិក

៨-លោក ឈ ឈុនសៀ មន្ត្រីនាយកដ្ឋានសោតទស្សន៍ ក្រសួងពត៌មាន ជាសមាជិក
៩-លោក មាស ទាំន់ធឿន ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ជាសមាជិក
១០-លោក ឆ្មី ម៉ុនធឿន ប្រធានផ្នែកនៃការិយាល័យនគរបាលសេដ្ឋកិច្ច សាលាក្រុងភ្នំពេញ ជាសមាជិក
១១-លោក ជៀប ឡុន មន្ត្រីនៅអយ្យការអមតុលាការក្រុងភ្នំពេញ ជាសមាជិក
១២-លោក ឌួន វណ្ណា មន្ត្រីនៅអយ្យការអមតុលាការក្រុងភ្នំពេញ ជាសមាជិក
១៣-លោក ខឹម សោភ័ណ មន្ត្រីក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ជាសមាជិក
១៤-លោកស្រី សាត សាលីម មន្ត្រីក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ជាសមាជិក
១៥-លោក សៀក សេដ្ឋា អនុប្រធានការិយាល័យសិល្បៈភាពយន្ត វីដេអូនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ជាសមាជិក
១៦-លោក គង់ វណ្ណារ៉ា មន្ត្រីការិយាល័យសិល្បៈភាពយន្ត វីដេអូនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ជាសមាជិក

ប្រការ ២ ._ គណៈកម្មការនេះ មានភារកិច្ច ៖

-សហការជាមួយគណៈកម្មការចំរុះ និងអាជ្ញាធរដែនដី គ្រប់ខេត្ត ក្រុង ក្នុងការអនុវត្តអនុក្រឹត្យ សារាចរ និងលិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យភាពយន្ត វីដេអូ ។

-តាមដានត្រួតពិនិត្យ ដើម្បីកែលំអ ពង្រឹង និងពង្រីកការងារទប់ស្កាត់បង្ក្រាប ព្រមទាំងបំបាត់ការធ្វើអាជីវកម្ម សេវាកម្មភាពយន្ត វីដេអូរ ខារ៉ាអូខេ អនាធិបតេយ្យទូទាំងប្រទេស ។

-ចូលពិនិត្យរោងបញ្ចាំងភាពយន្ត រោងបញ្ចាំងវីដេអូ កន្លែងធ្វើអាជីវកម្មខារ៉ាអូខេ ទូទាំងប្រទេស ក្នុងការចាក់បញ្ចាំងផលិតផល ភាពយន្ត វីដេអូ គ្រប់ប្រភេទ ។

-ត្រួតពិនិត្យកន្លែងធ្វើអាជីវកម្ម ជួល លក់ ខ្សែភាពយន្ត កាសែ្សត វីដេអូ និង ស៊ីឌីវីដេអូ គ្រប់ប្រភេទ លើការដាក់តាំងជួល លក់ នៅតាមទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។

-ធ្វើកំណត់ហេតុ រៀបចំសំណុំរឿងពាក់ព័ន្ធបទល្មើស និងរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

ប្រការ ៣ ៖ សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ ៤ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និង អតីតយុទ្ធជន សាលាក្រុងភ្នំពេញ តុលាការរាជធានីភ្នំពេញ នាយកដ្ឋានសិល្បៈភាពយន្ត និង ផ្សព្វផ្សាយវប្បធម៌ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្ត តាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★